# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

***********

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រ.ក/លេខ ០៥.០៨៩/០៩ គ.ជ.ប.អគ្គ.ពស**

រាជធានីភ្នំពេញ ថ្ងៃទី16 ខែឧសភា ឆ្នាំ ២០០៩

# អង្គការមិនមែនរដ្ឋាភិបាលជាតិចំនួន៨ នឹងចូលរួមសង្កេតការណ៍ឃ្លាំមើលការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឆ្នាំ២០០៩

សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ មានអង្គការមិនមែនរដ្ឋាភិបាលជាតិចំនួន ៨ បានដាក់អ្នកសង្កេតការណ៍ សរុបចំនួន ២៧០ នាក់ ចូលរួមសង្កេតមើលការបោះឆ្នោតនេះ ។

អង្គការសង្កេតការណ៍ទាំងនេះរួមមាន :

១- អង្គការលើកស្ទួយសុខុមាលភាពជនក្រីក្រ បានដាក់អ្នកសង្កេតការណ៍ចំនួន ៣៣ នាក់ក្នុងនោះមានស្ត្រីចំនួន ១៤ នាក់ និងចល័តចំនួន ២ នាក់ ។

២- អង្គការសហគមន៍ គ្រួសារអភិវឌ្ឍន៍កសិកម្ម បានដាក់អ្នកសង្កេតការណ៍ចំនួន២៨ នាក់ ក្នុងនោះស្ត្រីចំនួន៩ នាក់ និងចល័តចំនួន ៣ នាក់ ។

៣- អង្គការស្ត្រីខ្មែរអភិវឌ្ឍន៍វប្បធម៌ បានដាក់អ្នកសង្កេតការណ៍ចំនួន ៥១ នាក់ ក្នុងនោះស្ត្រីចំនួន ២៨ នាក់ និងចល័តចំនួន ៤ នាក់ ។

៤- អង្គការសេវាប្រជាធិបតេយ្យ បានដាក់អ្នកសង្កេតការណ៍ចំនួន ៤៨ នាក់ ក្នុងនោះស្ត្រីចំនួន ៨ នាក់ និងចល័តចំនួន ៤ នាក់ ។

៥- អង្គការសហព័ន្ធ និស្សិតបញ្ញវ័ន្ត ប្រជាធិបតេយ្យកម្ពុជា បានដាក់អ្នកសង្កេតការណ៍ចំនួន ១៧ នាក់ ក្នុងនោះស្ត្រីចំនួន ២ នាក់ ។

៦- អង្គការស្ត្រីសម្រាប់អភិវឌ្ឍន៍ សិទ្ធិមនុស្ស ឧស្សាហកម្ម កសិកម្ម បានដាក់អ្នកសង្កេតការណ៍ចំនួន ៤៥ នាក់ ក្នុងនោះស្ត្រីចំនួន ២៦ នាក់ និងចល័តចំនួន ៣ នាក់ ។

៧- អង្គការព្រហ្មវិហារធម៌នៃមាតា បានដាក់អ្នកសង្កេតការណ៍ចំនួន ៣៣ នាក់ ក្នុងនោះស្ត្រីចំនួន ១៨ នាក់ និងចល័តចំនួន ៣ នាក់ ។

៨- អង្គការអរុណោះ បានដាក់អ្នកសង្កេតការណ៍ចំនួន ១៥ នាក់ ក្នុងនោះស្ត្រីចំនួន ៩ នាក់ និងចល័តចំនួន ២ នាក់ ។

ដោយឡែកអ្នកសារព័ត៌មានជាតិ និងអន្តរជាតិ គ.ជ.ប បានផ្តល់ប័ណ្ណអ្នកសារព័ត៌មានសរុបចំនួន ២៧៦ នាក់ ដើម្បីចូលរួមយកព័ត៌មានទាក់ទងនឹងដំណើរការបោះឆ្នោតនេះ ។